ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ១៤..[illegible]..៦.៣ ង**

## សារលិខិតជូនពរ

### សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសបុណ្យខួបកំណើតគម្រប់ ៨៣ឆ្នាំ ឈានចូល ៨៤ឆ្នាំ នៅថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៧

សម្តេចអគ្គមហាពញាចក្រី ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់!

នៅក្នុងឱកាសដ៏មង្គលាភិសេកថ្ងៃថ្លា ប្រកបដោយសេចក្តីអភិរម្យសោមនស្សរីករាយ នៃបុណ្យខួបកំណើតគម្រប់ ៨៣ឆ្នាំ ឈានចូល ៨៤ឆ្នាំ របស់ សម្តេចអគ្គមហាពញាចក្រី ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០១៧ ខាងមុខនេះ តាងនាមសមាជិក សមាជិកានៃរាជរដ្ឋាភិបាលកម្ពុជា និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ព្រមទាំងភរិយា សូមសម្តែងនូវសេចក្តីសោមនស្សរីករាយដោយស្មោះអស់ពីដួងចិត្ត និងចូលរួមជូននូវសព្ទសាធុការពរជ័យ បវរមហាប្រសើរគ្រប់យ៉ាង ចំពោះ **សម្តេចអគ្គមហាពញាចក្រី ប្រធានរដ្ឋសភា** នៃព្រះរាជាណាចក្រកម្ពុជា សូមប្រកបទៅដោយសុខភាពល្អបរិបូរណ៍ បញ្ញាញាណភ្លឺថ្លាត្រចះត្រចង់ កាយពលមាំមួនខ្លាំងក្លា ជន្មាយុយឺនយូរតរៀងទៅ។ យើងខ្ញុំតែងតែនឹកឃើញ និងចងចាំជានិច្ច ប្រកបដោយការដឹងគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះទឹកចិត្ត និងសកម្មភាពស្នេហាជាតិ និងប្រជាជនរបស់ **សម្តេចអគ្គមហាពញាចក្រី** ដែលបានខិតខំយកអស់កម្លាំងកាយចិត្ត ប្រាជ្ញាស្មារតី និងបទពិសោធន៍ ប្រកបដោយគុណវិភាគដ៏ខ្ពង់ខ្ពស់របស់ **សម្តេច** ក្នុងការរួមចំណែកពង្រឹងនីតិរដ្ឋ លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ការគោរពសិទ្ធិមនុស្ស និងសេចក្តីថ្លៃថ្នូរជាមូលដ្ឋាន ការកែទម្រង់រដ្ឋស៊ីជម្រៅលើគ្រប់វិស័យ និងការកសាងសមិទ្ធផលសង្គមយ៉ាងច្រើនសម្រាប់ជាឧត្តមប្រយោជន៍ចំពោះជាតិមាតុភូមិ រួមចំណែកស្តារ និងអភិវឌ្ឍមាតុភូមិអង្គរជាទីស្នេហានៃយើង ឱ្យមានការរីកចម្រើនជឿនលឿនផុំផ្លើងរុងរឿងយ៉ាងឆាប់រហ័សរយៈកាលកន្លងមក។

ឆ្លៀតក្នុងឱកាសដ៏នក្ខត្តឫក្សវិសេសវិសាលជយាភិសេកនេះផងដែរ យើងខ្ញុំទាំងអស់គ្នាសូមលើកហត្ថប្រណម្យដល់វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក គុណបុណ្យព្រះរតនត្រ័យកែវទាំងបី ឫទ្ធិបារមីខ្លាំងក្លាព្រះអង្គចេក ព្រះអង្គចម ទេវតាថែរក្សាទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ពិសេសទេវតាថែរក្សាឆ្នាំថ្មី ព្រះនាម **កិមិរាទេវី** សូមព្រះអង្គតាមជួយអភិបាលប្រោសព្រំសព្ទសាធុការពរជ័យគ្រប់ប្រការចំពោះ **សម្តេចប្រធាន និងលោកជំទាវ** ព្រមទាំងបុត្រា បុត្រី បុត្រប្រសារ ចៅប្រុស ចៅស្រី ជាទីស្រឡាញ់ និងសូមសមប្រកបដោយពុទ្ធពរជ័យគ្រប់ឧត្តមថ្លៃថ្លាទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ ជានិច្ចនិរន្តរ៍កុំបីឃ្លៀងឃ្លាតឡើយ។

សូម សម្តេចអគ្គមហាពញាចក្រី ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា មេត្តាទទួលនូវការគោរពដ៏ជ្រាលជ្រៅពីខ្ញុំ និងភរិយា ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី.......ខែឧសភា ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**